# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 96

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : សាងសង់អគារស្នាក់នៅសម្រាប់ គ្រូនគរបាលជាតិ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/17

កាលបរិច្ឆេទបញ្ចប់គម្រោង 31/08/17

៣. ចំណាយគម្រោងសរុប $650,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងមហាផ្ទៃ

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹង និងការកែទម្រង់ស្ថាប័ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះចូលរួមចំណែកជួយជំរុញ និងលើកកម្ពស់គុណភាព ប្រសិទ្ធភាពការងារកសាងធនធានមនុស្សក្នុងជួរកងកម្លាំងប្រដាប់អាវុធ។

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិបាលកិច្ច និងរដ្ឋបាល Governance and Administration

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កណ្ដាល,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គម្រោងនេះ មានគោលបំណងបង្កើតកន្លែងស្នាក់នៅបណ្ដោះអាសន្នសម្រាប់សាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងគ្រូបរទេស ដែលត្រូវមកបង្ហាត់បង្រៀននៅបណ្ឌិត្យសភានគរបាលកម្ពុជា។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

ការសាងសង់អគារមានលក្ខណៈជាអន្តេវាសិក បណ្ដោយប្រវែង 25,20m ទទឹង 12,40m កំពស់ 3ជាន់ មាន 30បន្ទប់ ក្នុងបរិវេណបណ្ឌិត្យសភានគរបាលកម្ពុជា ស្ថិតនៅភូមិស្ពានកន្លែង ឃុំជីផង្គ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

បណ្ឌិត្យសភានគរបាលកម្ពុជា គឺជាស្ថាប័នបណ្ដុះបណ្ដាលកងកម្លាំងនគរបាលមួយដ៏សំខាន់ ដែលដើរតួនាទីបំរើ អោយប្រទេសជាតិទាំងមូលដែលមិនអាចខ្វះបាន។ ដោយសារស្ថាប័ននេះស្ថិតនៅរយៈចម្ងាយ ២៧ គីឡូម៉ែត្រ តាម បណ្ដោយផ្លូវជាតិលេខ១ ពីរាជធានីភ្នំពេញឆ្ពោះទៅក្រុងបាវិតនោះធ្វើអោយការធ្វើដំណើររបស់ សាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងគ្រូបរទេស ត្រូវបើកបរ រថយន្ត ឬ ម៉ូតូ មកបង្ហាត់បង្រៀនដល់សិក្ខាកាមទាំងមានការពើប ប្រទះនូវការលំបាកមួយចំនួន ដូចជា ការស្ទះចរាចរណ៍ និង ការប្រឈមបញ្ហាគ្រោះថ្នាក់ចរាចរផ្សេងៗ ការ ចំណាយបន្ថែមក្នុងការធ្វើដំណើរ ការចំណាយពេលវេលាច្រើនទាំងធ្វើដំណើ េរទៅ និងមក ដែលបញ្ហាទាំងនោះ អាចបណ្ដាលអោយមានការរាំងស្ទះទៅដល់ការបណ្ដុះបណ្ដាល និង គុណភាពផងដែរ។ ដូចនេះ បើសិន ជាអគារស្នាក់នៅរបស់សាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងគ្រូបរទេស ត្រូវបានផ្ដល់អោយនោះ ដំណោះស្រាយ មួយផ្នែកធំខាងលើត្រូវបានដោះស្រាយរួច ដែលជាការលើកទឹកចិត្តដល់សាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងគ្រូបរទេស អោយចង់មកបង្រៀន និងជាការលើកកិត្តយសដល់ បណ្ឌិត្យសភានគរបាលកម្ពុជា ក៏ដូចជាប្រទេសជាតិផងដែរ ។

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

គម្រោងនេះនឹងផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ដល់ បណ្ឌិត្យសភានគរបាលកម្ពុជាដើម្បីបំរើដល់ការអនុវត្ត ការបណ្ដុះបណ្ដាលមន្ត្រីនគរបាល និស្សិត សិក្ខាកាមជាមន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារ សាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងគ្រូបរទេស ទាំងអស់ ។ ដោយឡែក គម្រោងនេះនឹងផ្ដល់ផលប្រយោជន៍ដោយមិនផ្ទាល់ដល់ ប្រជាជនទូទាំងប្រទេសដែលបានទទួលសេវាសាធារណៈពីការបណ្ដុះបណ្ដាលប្រកបដោយចំណេះដឹង ជំនាញវិជ្ជាជីវៈ និងសមត្ថភាពពិតប្រាកដរបស់មន្ត្រីនគរបាលដែលចេញទៅបំរើការទាំងអស់។នឹងម៉្យាងវិញទៀតការអនុវត្តគម្រោង សាងសង់អគារក៏បានផ្ដល់ការងារដល់កម្លាំងពលកម្ម ក្នុងស្រុក និងចំណូលមួយចំនួន ក្នុងរយៈពេលនៃការអនុវត្ត ផងដែរ ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ ? **មិនទាន់ចាប់ផ្ដើម**

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម ( ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ ? )

គម្រោងនេះ មិនបង្កផលប៉ះពាល់ដល់ប្រជាជន និងបរិស្ថានជុំវិញទេ តែបានចូលរួមចំណែកដល់ការកាត់បន្ថយភាព ក្រីក្រ ដោយបានជួយកាត់បន្ថយការចំណាយរបស់សាស្ត្រាចារ្យ គ្រូនគរបាលជាតិ និងគ្រូបរទេស ដែលត្រូវបង្រៀន នៅទីនោះ ព្រមទាំងជួយបង្កើតអាជីវកម្មខ្នាតតូចដល់ប្រជាជនក្នុងតំបន់។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

## ២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**មិនមាន**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មាន**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**មិនមាន**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនមាន**

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចន្ទ |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 50.0 | 0.0 | 0.0 | 50.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 50.0 | 0.0 | 0.0 | 50.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 600.0 | 0.0 | 0.0 | 600.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 550.0 | 0.0 | 0.0 | 550.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 50.0 | 0.0 | 0.0 | 50.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 650.0 | 0.0 | 0.0 | 650.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 650.0 | 0.0 | 0.0 | 650.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: